# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
## អភិបូជាចិនសិក្ខាសាលាសិល្បៈ
## ចំការទៀន ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៩
## របៀបកសាងទីដៅ

**អត្ថបទទី១៖ បេនស៊ីរ៉ាក់ ៣៥,១៥ខ-១៧.២០-២២ក**

ពាក្យអង្វររបស់មនុស្សទន់ទាប ពិតជារសាត់ទៅដល់ស្ថានបរមសុខ។ បើព្រះអម្ចាស់មិនឆ្លើយតបទេ គេមិនព្រមឈប់ព្រួយឡើយ គេនៅតែទទូចអង្វរឥតឈប់ឈរ ទាល់តែព្រះដ៏ខ្ពង់ខ្ពស់បំផុតអាណិតគេ។ បសរ ៣៥,២១

**អត្ថបទទី២៖ ធីម៉ូថេទី២ ៤,៦-៨.១៦-១៨**

មានតែព្រះអម្ចាស់ប៉ុណ្ណោះដែលបានគាំទ្រ និងប្រទានឲ្យខ្ញុំមានកម្លាំង ដើម្បីឲ្យខ្ញុំអាចប្រកាសព្រះបន្ទូលយ៉ាងក្បោះក្បាយឲ្យសាសន៍ដទៃទាំងអស់គ្នាស្ដាប់។ ២ធម ៤,១៧ក

**ដំណឹងល្អ៖ លូកា ១៨,៩-១៤**

អ្នកណាលើកតម្កើងខ្លួន អ្នកនោះនឹងត្រូវគេបន្ទាបចុះ រីឯអ្នកដែលបន្ទាបខ្លួននឹងត្រូវគេលើកតម្កើងវិញ។ លក ១៨,១៤ខ

បងប្អូនជាទីស្រឡាញ់!

អត្ថបទទីពីរ "**ខ្ញុំបានបូជាជីវិតរួចស្រេចហើយ ហើយក៏ដល់ពេលកំណត់ដែលខ្ញុំត្រូវចាកចេញពីលោកនេះដែរ ខ្ញុំបានពុះពារតយុទ្ធល្អប្រសើរ ខ្ញុំបានរត់ដល់ទីដៅ ឥឡូវនេះព្រះអម្ចាស់ជាចៅក្រមដ៏សុចរិត បានបម្រុងភួងជ័យនៃសេចក្ដីសុចរិតទុកសម្រាប់ខ្ញុំ**" នេះជាសំដីរបស់លោកប៉ូលនៅថ្ងៃចុងក្រោយនៃជីវិតគាត់។ មានន័យថា នៅក្នុងជីវិតរបស់លោកប៉ូលគាត់បានរៀបចំគម្រោងការ ទីដៅមួយយ៉ាងច្បាស់ដើម្បីធ្វើដំណើរពីមួយថ្ងៃទៅមួយថ្ងៃ។ សម្រាប់បងប្អូន **តើយើងមានទីដៅអ្វីខ្លះសម្រាប់ជីវិតរបស់យើង?** នៅថ្ងៃចុងក្រោយនៃជីវិតរបស់យើង **តើយើងបានបំពេញទីដៅរបស់ខ្លួនឬនៅ?** ខ្ញុំមានបីចំណុចដើម្បីកសាងទីដៅរបស់យើង៖

**ចំណុចទីមួយ សុចរិត** នៅក្នុងអត្ថបទគម្ពីរដំណឹងល្អមានម្នាក់ដែលបង្ហាញថាខ្លួនជាមនុស្សសុចរិត និងមានម្នាក់ទៀតដែលបានដាក់ខ្លួនហើយបង្ហាញថាខ្លួនជាមនុស្សបាប។ យើងបានឃើញមនុស្សម្នាក់ដែលអួតខ្លួនថាជាមនុស្សល្អ និងឃើញម្នាក់ទៀតដែលដាក់ខ្លួនទទួលស្គាល់អំពើបាបរបស់ខ្លួន ដើម្បីកែប្រែចិត្តគំនិត។ នៅក្នុងរបាំដែលយើងបានហាត់ ហានុមាន(ស្វា)ជានិមិត្តរូបនៃអំពើល្អ និងយក្សជានិមិត្តរូបនៃអំពើអាក្រក់ ជីវិតរបស់យើងគឺចេះតែប្រឆាំងគ្នារវាងអំពើល្អនិងអំពើអាក្រក់។ គោលដៅនៃជីវិតរបស់យើង ធ្វើដូចម្ដេចដើម្បីបន្តិចម្ដងៗយកឈ្នះភាពងងឹតដែលយើងមាននៅក្នុងខ្លួន ដើម្បីរស់នៅក្នុងពន្លឺ ឈ្នះអំពើអាក្រក់ដើម្បីធ្វើអំពើល្អ។ អស់

មួយជីវិតរបស់យើង យើងធ្វើដូចម្តេចដើម្បីចេញស្នាដៃរបស់យើង ធ្វើដូចម្តេចដើម្បីទៅជាមនុស្សសុចរិត។ មានន័យថា យើងជាមនុស្សម្នាក់ដែលរស់នៅក្នុងយុត្តិធម៌ ដែលខិតខំធ្វើអំពើល្អ ដែលខិតខំស្រឡាញ់បងប្អូនឯទៀតៗ ដែលខិតខំលើកលែងទោសឲ្យអ្នកដទៃ ដែលខិតខំធ្វើជាសិស្សល្អ មិត្តល្អ និងពលរដ្ឋល្អ។ នៅក្នុងដួងចិត្តរបស់យើង យើងជាហនុមានផងយើងជាយក្សផង ពន្លឺនិងភាពងងឹតធ្វើដំណើរជាមួយគ្នា យើងធ្វើដូចម្តេចដើម្បីឲ្យពន្លឺចេញរស្មីដើម្បីបំភ្លឺបងប្អូនឯទៀតៗ។ ព្រះយេស៊ូ ឲ្យយើងយកចិត្តទុកដាក់កែប្រែចិត្តគំនិត ពេលខ្ញុំធ្វើខុសខ្ញុំទទួលស្គាល់អំពីកំហុសរបស់ខ្លួនហើយខិតខំកែប្រែ។

**ចំណុចទីពីរ យកចិត្តទុកដាក់** នៅក្នុងអត្ថបទទីមួយ "**អ្នកគោរពព្រះជាម្ចាស់ដោយស្មោះអស់ពីចិត្ត**" ឲ្យយើងទៅជាមនុស្សដែលគោរពបម្រើព្រះជាម្ចាស់ដោយស្មោះអស់ពីចិត្ត។ ឲ្យយើងចេះគោរពព្រះជាម្ចាស់ គោរពបងប្អូនឯទៀតៗអស់ពីចិត្ត មានន័យថាឲ្យយើងធ្វើជាមនុស្សដែលចេះគោរពផង និងដែលចេះយកចិត្តទុកដាក់ដល់បងប្អូនអស់ពីចិត្តផង។ របៀបដែលយើងរៀបចំខ្លួននៅក្នុងសិល្បៈ យើងបានយកចិត្តទុកដាក់ពិតមែនដោយសារអ្នកសិល្បៈមិនអាចប្រហែលៗបានទេ។ យើងបានយកចិត្តទុកដាក់អស់ពីដួងចិត្ត ដើម្បីឲ្យកាយវិការនីមួយៗ ឲ្យក្បាច់នីមួយៗត្រឹមត្រូវ ដោយគោរពវិន័យ គោរពសីលធម៌។ ឲ្យយើងយកចិត្តទុកដាក់នៅគ្រប់ការងារដែលយើងធ្វើ ដោយភាពស្មោះត្រង់ ដើម្បីឲ្យអ្វីៗដែលយើងធ្វើមានតម្លៃ។

**ចំណុចទីបី កំណត់ទីដៅ** នៅក្នុងអត្ថបទទីពីរ "**មានតែព្រះអម្ចាស់ប៉ុណ្ណោះ ដែលបានគាំទ្រនិងប្រទានឲ្យខ្ញុំមានកម្លាំង ដើម្បីឲ្យខ្ញុំអាចប្រកាសព្រះបន្ទូលយ៉ាងក្បោះក្បាយឲ្យសាសន៍ដទៃទាំងអស់គ្នាស្តាប់**"។ ព្រះជាម្ចាស់បានជ្រើសរើសយើង ដើម្បីឲ្យយើងប្រកាសដំណឹងល្អយ៉ាងក្បោះក្បាយឲ្យសាសន៍ដទៃទាំងអស់គ្នាស្តាប់ និងឲ្យយើងពោរពេញដោយកម្លាំង។ គ្រីស្តបរិស័ទយើងចេញទៅបង្ហាញខ្លួនដើម្បីប្រកាសដំណឹងល្អយ៉ាងច្បាស់ ដោយមានកម្លាំងនិងមានគោលដៅ **តើខ្ញុំធ្វើដូចម្តេចដើម្បីប្រកាសដំណឹងល្អ?** សម្រាប់យើងជាក្រុមសិល្បៈ ឲ្យយើងប្រកាសដំណឹងល្អតាមរយៈសិល្បៈ តាមរបៀបដែលយើងសម្តែងដើម្បីចែករំលែកអំណរសប្បាយដែលយើងមាន។ យើងត្រូវរិះគិតជាមួយលោកបូជាចារ្យបងប្រុសបងស្រី នៅតាមព្រះសហគមន៍នីមួយៗ យើងអាចធ្វើអ្វីខ្លះនៅក្នុងប្រពៃណីយើង នៅក្នុងសិល្បៈដែលយើងសម្តែង អាចធ្វើឲ្យបងប្អូនឯទៀតៗមានអំណរសប្បាយជាមួយយើង។

សរុបសេចក្តី យើងជាមនុស្សដែលមានអំពើល្អផងនិងអំពើអាក្រក់ផង យើងធ្វើដូចម្តេចដើម្បីឲ្យហនុមានយកឈ្នះយក្សនៅក្នុងជីវិតរបស់យើងជានិច្ច។ យើងជាមនុស្សដែលគោរពបម្រើ និងយកចិត្តទុកដាក់ នៅក្នុងគ្រប់កាលៈទេសៈនៃជីវិតរបស់យើង។ យើងធ្វើដូចម្តេចដើម្បី

ថែរក្សាគោលដៅមួយយ៉ាងពិសេស គឺប្រកាសព្រះបន្ទូលយ៉ាងក្បោះក្បាយឲ្យសាសន៍ដទៃទាំងអស់បានស្ដាប់ មានន័យថាឲ្យបងប្អូនឯទៀតៗបានស្ដាប់ បានឃើញ តាមរយៈសិល្បៈរបស់យើង គេអាចស្ដាប់ព្រះបន្ទូលដំណឹងល្អបាន។

យើងអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គប្រទានព្រះពរឲ្យព្រះសហគមន៍របស់យើងក្នុងភូមិភាគភ្នំពេញ ទៅជាព្រះសហគមន៍មួយដែលចូលយ៉ាងជ្រៅនៅក្នុងវប្បធម៌ខ្មែរយើង ដើម្បីឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៅជាព្រះបន្ទូលដែលរស់នៅក្នុងទឹកដីយើង ដែលចាក់ឫសនៅលើទឹកដីយើង ដើម្បីឲ្យគ្រប់ការប្រកាសរបស់យើង គ្រប់កាយវិការរបស់យើង គ្រប់ស្នាដៃរបស់យើង អាចចូលយ៉ាងជ្រៅនៅក្នុងដួងចិត្តរបស់បងប្អូនឯទៀតៗ ដោយយើងចេះឆ្លើយតបសេចក្ដីត្រូវការរបស់គេនៅក្នុងសេចក្ដីស្រឡាញ់ដែលយើងបានទទួលពីព្រះជាម្ចាស់ ដែលជាម្ចាស់នៃជីវិតរបស់យើង។ អាម៉ែន៕